# ការសម្ភាសន៍របស់អ៊ុំស្រី សុខ សោ

កះ អ្នកសំភាសន៍ឈ្មោះ គង់ ចាន់ណាក់ ខះ អ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ សុខ សោ

ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ សុខ សោ

សង្ខេបះ អ៊ុំស្រី សុខ សោ គាត់មានអាយុចិតសិបប្រាំឆ្នាំ ហើយគាត់បានកើតនៅភូមិជប់ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
គាត់មានបងប្អូនចំនួនប្រាំបីនាក់តែបានស្លាប់អស់ហើយនៅសល់តែបីនាក់ទេ ហើយគាត់ជាកូនទីមួយនៅក្នុងក្រុមគ្រួសារ។
ក្នុងពាក់កណ្តាលជំនាន់ពលពតឪពុករបស់គាត់ត្រូវបានពលពតយកទៅសំលាប់ចោល ហើយសំរាប់ម្តាយរបស់គាត់ទើបតែស្លាប់ប្រហែលពីរបីខែនឹងទេ។
គាត់មានកូនស្រីម្នាក់តែគួរអោយសោកស្តាយកូនរបស់គាត់បានស្លាប់នៅពេលគាត់បានអាយុម្ភៃឆ្នាំ ដោយសារជម្ងឺ។ ហើយនៅក្នុងជំនាន់ពលពតគេបានអោយគាត់ទៅអូសអួននៅទន្លេ។
ក្នុងជីវិតរបស់គាត់មានការលំបាកច្រើន
ហើយនៅពេលនេះគាត់មានការលំបាកដោយសារគាត់មានជម្ងឺច្រើនហើយគាត់រកអីអត់បានទេ គាត់រស់នៅដោយពឹងពាក់លើប្អូនរបស់គាត់។ធ្វើឡើងនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៨ ខែ០៦ ឆ្នាំ២០១៨៕

កះ អញ្ចឹងជំរាបសួរអ៊ុំស្រី ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិចឈ្មោះ ថាសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដោយសារសាកលវិទ្យាល័យមានគម្រោងដើម្បីជួយថៃរក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរយើងសំរាប់ទុកអោយកូនចៅជំនាន់ក្រោយពួកគាត់អាចស្គាល់ពីប្រវត្តិរបស់ជីដូនជីតាហើយនឹងឪពុកម្តាយ។ ហើយសំរាប់ការសម្ភាសន៍របស់យើងធ្វើនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយយើងធ្វើនៅថ្ងៃទី២៨ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹងសំរាប់អ៊ុំស្រីសំរាប់ការសម្ភាសន៍នឹងយើងនឹងថតជាសំលេង ហើយនឹងរូបភាពអ៊ុំស្រី ដើម្បីយើងអាចផ្ញើរទៅកាន់សាកលវិទ្យាល័យ ដើម្បីសាកលវិទ្យាល័យអាចយករូបភាពហើយនឹងសំលេងរបស់អ៊ុំស្រីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ អញ្ចឹង តើអ៊ុំស្រីយល់ព្រមអោយយើងយកសំលេង ហើយនឹងរូបភាពរបស់អ៊ុំស្រីដាក់លើវេបសាយរបស់សាកលវិទ្យាល័យទេ អ៊ុំស្រី?

ខះ ព្រម។

កះ អញ្ចឹងអរគុណច្រើនអ៊ុំស្រីដែលបានអនុញ្ញាតិអោយយើងយករូបភាពហើយនឹងសំលេងរបស់អ៊ុំស្រីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹងដំបូងខ្ញុំសុំសួរអ៊ុំស្រី តើអ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខះ ខ្ញុំឈ្មោះ សុខ សោ។

កៈ សុខ សោ! ហើយអញ្ចឹងសំរាប់អ៊ុំស្រី តើអ៊ុំស្រីមានឈ្មោះហៅក្រៅទេ អ៊ុំស្រី?

ខៈ អត់មានទេ។

កៈ អូ! អត់មានទេអ៊ុំស្រី! ហើយអញ្ចឹង កាលដែលអ៊ុំស្រីនៅក្មេង តើគេហៅឈ្មោះរបស់អ៊ុំស្រីថាម៉េចដែរអ៊ុំស្រី?

ខៈ គេហៅឈ្មោះចឹងតែម្តង។

កៈ អូ! ចឹងគេហៅឈ្មោះរបស់អ៊ុំស្រីថា សោ ចឹងតែម្តង?

ខៈ ហ្នឹងហើយ។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខៈ សព្វថ្ងៃនេះខ្ញុំមានអាយុចិតសិបឆ្នាំ។

កៈ អូ! អ៊ុំស្រីអាយុចិតសិបឆ្នាំគត់តែម្តង ឬអ៊ុំស្រី?

ខៈ ចិតសិបប្រាំឆ្នាំហើយ។

កៈ អូ! អញ្ចឹងសព្វថ្ងៃនេះអ៊ុំស្រីមានអាយុចិតសិបប្រាំឆ្នាំហើយ អ៊ុំស្រី។ ហើយអញ្ចឹង តើអ៊ុំស្រីនៅចាំទេថាអ៊ុំស្រីបានកើតនៅក្នុងឆ្នាំណាទេ អ៊ុំស្រី?

ខៈ អត់ដឹងទេ។

កៈ អត់ដឹងទេអ៊ុំស្រី អញ្ចឹងអ៊ុំស្រីមានអាយុចិតសិបប្រាំឆ្នាំ ចឹងសំរាប់អ៊ុំស្រីកើតប្រហែលជាឆ្នាំមួយពាន់ប្រាំបួនរយសែសិបបី។ ហើយអញ្ចឹង អ៊ុំស្រីចាំទេថាអ៊ុំស្រីបានកើតក្នុងឆ្នាំខ្មែរយើង ដូចជា ជូត ឆ្លូត ខាល ថោះ តើអ៊ុំស្រីបានកើតក្នុងឆ្នាំណាទេ អ៊ុំស្រី?

ខៈ ខ្ញុំកើតឆ្នាំចរ។

កៈ អូ! អ៊ុំស្រីបានកើតឆ្នាំចរ។ ហើយអញ្ចឹង តើអ៊ុំស្រីបានកើតនៅក្នុងខេត្តណាដែរ អ៊ុំស្រី?

ខៈ ខ្ញុំកើតនៅក្នុងស្រុកជប់។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីមាននៅចាំឈ្មោះភូមិ ឃុំ ស្រុកទេ អ៊ុំស្រី?

ខៈ ភូមិជប់ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

កៈ ហើយអញ្ចឹង សំរាប់អ៊ុំស្រី តើអ៊ុំស្រីមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខៈ ខ្ញុំមានបងប្អូនចំនួនប្រាំបីនាក់ប៉ុន្តែស្លាប់អស់ហើយ នៅតែស្រីបីនាក់ទេ។

កៈ ស្លាប់អស់ហើយនៅសល់តែបីនាក់ទេ អញ្ចឹង បងប្អូនប្រាំបីនាក់តែស្លាប់អស់ហើយ។ ហើយអញ្ចឹង សំរាប់អ៊ុំស្រីជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារដែរ អ៊ុំស្រី?

ខៈ ខ្ញុំជាកូនទីមួយ។

កៈ អូ! អញ្ចឹងអ៊ុំស្រីជាបងគេ! ហើយអញ្ចឹងសំរាប់បងប្អូនទាំងប្រាំនាក់របស់អ៊ុំស្រី តើមានស្រីប៉ុន្មានហើយប្រុសប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខៈ បងប្អូនរបស់ខ្ញុំមានស្រីបួននាក់ ហើយប្រុសបួននាក់។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនរបស់អ៊ុំស្រីទាំងប្រាំនាក់បានទេ អ៊ុំស្រីមាននៅចាំឈ្មោះពួកគាត់ទេ?

ខៈ ខ្ញុំឈ្មោះសុខ សោ ហើយប្អូនរបស់ខ្ញុំនៅសួងឈ្មោះ សុខ បាន ហើយបន្ទាប់មកទៀត សុខ ធី ហើយបន្ទាប់មក សុខ កួន មកទៀត សុខ លី ហើយមកទៀត សុខ នី ហើយមួយទៀតឈ្មោះ សុខ ក្រេច ស្រីដែរ។

កៈ ហើយអញ្ចឹង កាលនៅក្មេង តើអ៊ុំស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ៊ុំស្រី?

ខៈ នៅពីក្មេងមកស៊ីតែឈ្នួលគេ ដកស្ទូងនឹង គ្មានធ្វើអីទេ។

កៈ អញ្ចឹង ពេលទៅដកស្ទូងនឹង ទៅទាំងអស់គ្នា។

ខៈ ប្អូនទៅរៀនទៅ យើងនឹងទៅដកស្ទូងបានលុយបានកាក់មកអោយម៉ែទៅទិញម្ហូបហូបទៅ។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះបងប្អូនរបស់អ៊ុំស្រីស្លាប់អស់ប្រាំនាក់ហើយ
នៅសល់តែបីនាក់ទេ។ ហើយអញ្ចឹង
តើបងប្អូនរបស់អ៊ុំស្រីពួកគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ៊ុំស្រី?

ខៈ ពួកគាត់ស្លាប់ក្នុងជំនាន់ពលពត។

កៈ អូ! ពួកពលពតយកទៅវាយចោល។ ហើយអញ្ចឹង តើពួកគាត់បានស្លាប់ប្រហែលឆ្នាំណាដែរ អ៊ុំស្រីមាននៅចាំទេ?

ខៈ រឿងឆ្នាំនឹងខ្ញុំដូចជាមិនសូវចាំសោះ តែគ្រាន់តែដឹងថាពួកគាត់បានស្លាប់ក្នុងជំនាន់ពលពត។

កៈ ហើយអញ្ចឹង ពេលដែលពួកគាត់ស្លាប់នឹង បានពាក់កណ្ដាលជំនាន់ពលពតហើយ ឬទើបតែចាប់ផ្ដើមទេពេលស្លាប់នឹង?

ខៈ ពួកគាត់ស្លាប់ពាក់កណ្ដាលជំនាន់ពលពត។

កៈ អូ! អញ្ចឹងពាក់កណ្ដាលជំនាន់ពលពតគេយកពួកគាត់ទៅវាយចោល។ ហើយអញ្ចឹង សំរាប់បងប្អូនដែលនៅសល់នឹងសព្វថ្ងៃនេះពួកគាត់រស់នៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ មួយនៅឯកែរសីម៉ា ហើយមួយទៀតនៅនឹង។

ក៖ អូ! ម្នាក់នៅភូមិនឹងដែរ ហើយម្នាក់ទៀតនៅឯកែរសីមា ខេត្តរតនគីរី។ ហើយអញ្ចឹង សំរាប់ម្តាយរបស់អ៊ុំស្រី តើគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ អ៊ឹម ស៊ឹង ហើយឪពុករបស់ខ្ញុំគាត់ឈ្មោះ សុខ សាន់។

ក៖ អូ! ឪពុករបស់អ៊ុំស្រីគាត់ឈ្មោះ សុខ សាន់។ ហើយអញ្ចឹង តើម្តាយរបស់អ៊ុំស្រីគាត់បានកើតពេលណា អ៊ុំស្រីដឹងទេ?

ខ៖ អត់ដឹងទេ។

ក៖ ហើយអញ្ចឹង ម្តាយរបស់អ៊ុំស្រីគាត់កើតឆ្នាំខ្មែរ ឆ្នាំជូត ឆ្លូត ខាល ថោះ តើគាត់កើតអ្វី អ៊ុំស្រីដឹងទេ?

ខ៖ ម្តាយរបស់ខ្ញុំគាត់កើតឆ្នាំកុរ។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះគាត់បានស្លាប់ហើយ អ៊ុំស្រី?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់ហើយ គាត់ស្លាប់ប្រហែលពីរបីខែហើយ។

ក៖ អូ! អញ្ចឹងម្តាយរបស់អ៊ុំស្រីគាត់ទើបតែស្លាប់ទេ គាត់ទើបតែស្លាប់បានពីរបីខែនឹងទេ អញ្ចឹង គាត់បានស្លាប់ក្នុងឆ្នាំនឹង។

ខ៖ ហ្នឹងហើយ គាត់ស្លាប់ឆ្នាំនឹង។

ក៖ ហើយអញ្ចឹង ពេលដែលម្តាយរបស់អ៊ុំស្រីស្លាប់នឹង តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយអ៊ុំស្រី?

ខ៖ ខ្ញុំមានអាយុចិតសិបប្រាំនឹង។

ក៖ អូ! អ៊ុំស្រីមានអាយុចិតសិបប្រាំឆ្នាំ។ ហើយអញ្ចឹង កាលដែលម្តាយរបស់អ៊ុំស្រីគាត់នៅរស់ តើគាត់ប្រកបមុខរបរអ្វីដែរ អ៊ុំស្រី?

ខ៖ ម្តាយរបស់ខ្ញុំគាត់មិនសូវធ្វើអ្វីទេ គាត់នៅតែផ្ទះនឹង តែខ្ញុំអីនឹងចេះតែរកទៅ អោយគាត់អីហូប ចឹងទៅ តាំងពីដើមមកម្តាយរបស់ខ្ញុំមិនដែលធ្វើអីទេ។

ក៖ ហើយអញ្ចឹង តើម្តាយរបស់អ៊ុំស្រីគាត់ជាមនុស្សបែបណាដែរ អ៊ុំស្រី ដូចជាចរិតរបស់គាត់ ស្លូតបូត ឬក៏យ៉ាងម៉េចដែរ?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លូត គាត់អត់មានកាចទេ គាត់មិនដែលជេរកូនជេរចៅផង។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំស្រី តើគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ សុខ សាន់។

កៈ សុខ សាន់!

ខៈ ឪពុករបស់ខ្ញុំគាត់ដូចព្រះចឹង ស្រាក៏គាត់មិនហូបដែរ។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំស្រីគាត់កើតនៅពេលណា អ៊ុំស្រីមាននៅចាំទេ?

ខៈ អត់ចាំផង។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំស្រីគាត់កើតឆ្នាំខ្មែរឆ្នាំអ្វីដែរ អ៊ុំស្រី?

ខៈ ឪពុករបស់ខ្ញុំគាត់កើតឆ្នាំច។

កៈ អូ! ឪពុករបស់អ៊ុំស្រីគាត់កើតឆ្នាច។ ហើយអញ្ចឹង តើឪពុករបស់អ៊ុំស្រីគាត់កើតនៅកន្លែងណាដែរ អ៊ុំស្រី ស្រុកកំណើតរបស់គាត់?

ខៈ ស្រុកកំណើតរបស់ឪពុកខ្ញុំនៅខេត្តកណ្ដាល។

កៈ ហើយអញ្ចឹង ឪពុករបស់អ៊ុំស្រីគាត់បានស្លាប់ហើយ អ៊ុំស្រី?

ខៈ ឪពុករបស់គាត់ស្លាប់ហើយ គាត់ស្លាប់យូរហើយប្រហែលជាម្ភៃឆ្នាំហើយ។

កៈ អូ! ឪពុករបស់អ៊ុំស្រីគាត់បានស្លាប់ប្រហែលម្ភៃឆ្នាំហើយ។ ហើយអញ្ចឹង ពេលដែលឪពុករបស់អ៊ុំស្រីគាត់បានស្លាប់ តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខៈ ពេលដែលឪពុកខ្ញុំគាត់ស្លាប់ខ្ញុំនៅអាយុប្រហែលជាសាមជាង។

កៈ អូ! អញ្ចឹងគាត់ស្លាប់យូរហើយមិនមែនម្ភៃឆ្នាំទេ បើពេលគាត់ស្លាប់អ៊ុំស្រីអាយុសាមជាង ហើយឥលូវអ៊ុំស្រីអាយុចិតសិបប្រាំឆ្នាំហើយ ប្រហែលចូលសែសិបឆ្នាំហើយ។ ហើយអញ្ចឹង តើឪពុករបស់អ៊ុំស្រីគាត់បានស្លាប់នៅមុខជំនាន់ពលពតទៀតមែនទេ?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់ក្នុងជំនាន់ពលពតនឹងណា។

កៈ អូ! អញ្ចឹងគាត់បានស្លាប់ក្នុងជំនាន់ពលពត។ ហើយអញ្ចឹង ឪពុករបស់អ៊ុំស្រីគាត់បានស្លាប់នៅភូមិនឹងដែរ ឬមួយគាត់ស្លាប់នៅកន្លែងណា?

ខៈ ឪពុករបស់ខ្ញុំគាត់បានស្លាប់នៅភូមិនឹង។

កៈ អញ្ចឹងបានន័យថា កាលជំនាន់ពលពតគេអត់បានជំលៀសទៅកន្លែងណាទេ នៅនឹងភូមិនឹងដដែល។

ខៈ ហ្នឹងហើយ! នៅនឹងភូមិនឹង។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំស្រីកាលគាត់នៅរស់ តើគាត់ប្រកបមុខរបរអ្វីដែរ អ៊ុំស្រី?

ខ៖ ឪពុករបស់ខ្ញុំគាត់ធ្វើការអោយបារាំងនៅកាំ៉ស។

ក៖ ហើយអញ្ចឹង គាត់ធ្វើជាជាង ឬមួយគាត់ធ្វើអ្វីដែរ អ៊ុំស្រី?

ខ៖ គាត់យាមកាំ៉សអោយគេ។

ក៖ ហើយអញ្ចឹងសំរាប់ឪពុករបស់អ៊ុំស្រី តើគាត់ជាមនុស្សបែបណាដែរសំរាប់ចរិតគាត់?

ខ៖ ឪពុករបស់ខ្ញុំចរិតគាត់ស្លូត មិនសូវមាត់មិនសូវក៏អីទេ។

ក៖ ហើយអញ្ចឹង អ៊ុំស្រីមាននៅចាំពីខ្សែជីវិតរបស់គាត់ទេ កាលគាត់នៅក្មេងអី?

ខ៖ ខ្ញុំអត់ដឹងទេ។

ក៖ ហើយអញ្ចឹង គាត់អត់ធ្លាប់ប្រាប់អ៊ុំស្រីពីជីវិតគាត់ កាលគាត់នៅក្មេងៗទេ អ៊ុំស្រី?

ខ៖ គាត់មិនដែលប្រាប់ទេ។

ក៖ អូ! គាត់អត់ដែលប្រាប់អ៊ុំស្រីទេ។ ហើយអញ្ចឹង
អ៊ុំស្រីមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ៊ុំស្រីទេ?

ខ៖ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំគាត់ឈ្មោះ យាយ អ៊ុន តា អ៊ឹម។

ក៖ យាយ អ៊ុន តា អ៊ឹម! ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ៊ុំស្រីគាត់បានកើតនៅកន្លែងណា
អ៊ុំស្រីមាននៅចាំទេ?

ខ៖ ខ្ញុំមិនដឹងថាគាត់កើតនៅណាទេ
តែគ្រាន់តែពេលខ្ញុំកើតមកឃើញគាត់រស់នៅនឹងភូមិជប់នឹងតែម្ដង។

ក៖ អូ! អញ្ចឹងមានន័យថាអ៊ុំស្រីកើតមកបានជួបជាមួយគាត់ដែរ។ ហើយអញ្ចឹង តើជីដូនជីតាខាង
ម្ដាយរបស់អ៊ុំស្រីគាត់បានកើតពេលណា អ៊ុំស្រីដឹងទេ?

ខ៖ អត់ដឹងដែរ។

ក៖ អ៊ុំស្រីអត់ដឹងទេ! ហើយអញ្ចឹង
តើជីដូនជីតាខាងម្ដាយរបស់អ៊ុំស្រីគាត់បានស្លាប់ប្រហែលប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខ៖ អូ! មិនដឹងប៉ុន្មានឆ្នាំទេ ពួកគាត់ស្លាប់តាំងពីខ្ញុំនៅតូច។

ក៖ អូ! គាត់ស្លាប់តាំងពីអ៊ុំស្រីនៅតូច។
ហើយអញ្ចឹងសំរាប់អ៊ុំស្រីធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ទេ
គាត់ធ្លាប់ធ្វើអីអោយអ៊ុំស្រីសប្បាយចិត្តទេ?

ខ៖ គាត់មិនដែលធ្វើអីអោយទេ គាត់មិនដែលថាអីអោយខ្ញុំផង។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីនៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ៊ុំស្រីទេ?

ខៈ ជីដូនជីតាខាងឪពុករបស់ខ្ញុំ ខ្ញុំអត់ចាំទេ ខ្ញុំចាំតែជីដូនជីតាខាងម្ដាយរបស់ខ្ញុំទេ។

កៈ ហើយអញ្ចឹង
ពេលដែលអ៊ុំស្រីកើតមកអត់ដែលបានជួបជាមួយជីដូនជីតាខាងឪពុករបស់អ៊ុំស្រីទេ?

ខៈ អត់ដែលបានជួបទេ។

កៈ អូ! ដោយសារពួកគាត់បានស្លាប់អស់ហើយ។ ហើយអញ្ចឹង
សំរាប់ក្រុមគ្រួសាររបស់អ៊ុំស្រីបានរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខៈ ខ្ញុំនៅនេះដឹងប៉ុន្មានឆ្នាំទេអត់សូវដឹងដែរ ព្រោះអីមកនៅនេះតាំងពីនៅតូច
ហើយរហូតមកដល់ឥលូវនេះដឹងប៉ុន្មានឆ្នាំហើយទេ។

កៈ អញ្ចឹងមានន័យថា អ៊ុំស្រីមកនៅខេត្តនេះតាំងពីអ៊ុំស្រីបានកើតមកម្លេះ។ ហើយអញ្ចឹង
សំរាប់អ៊ុំស្រីមានសាច់ញាតិដែលរស់នៅក្រៅប្រទេសខ្មែរទេ?

ខៈ គ្មានបងប្អូនណានៅក្រៅពីប្រទេសខ្មែរយើងទេ។

កៈ ហើយអញ្ចឹង សំរាប់ស្វាមីរបស់អ៊ុំស្រីគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខៈ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ តា ជឹម។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំណាដែរ អ៊ុំស្រីមាននៅចាំទេ?

ខៈ ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ក្នុងជំនាន់ពលពត។

កៈ ហើយអញ្ចឹង ប្រហែលជាក្នុងឆ្នាំចិតប៉ុន្មានដែរ អ៊ុំស្រីនៅចាំទេ?

ខៈ មិនដឹងជាចិតប៉ុន្មានទេ ខ្ញុំមិនសូវចាំដែរនឹង។

កៈ ហើយអញ្ចឹង ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខៈ ពេលរៀបអាពាហ៍ពិពាហ៍នឹងខ្ញុំអាយុសែជាងហើយ។

កៈ ហើយអញ្ចឹង ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង នៅកន្លែងណាដែរ អ៊ុំស្រី?

ខៈ នៅភូមិនឹងតែម្ដង។

កៈ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុកម្ដាយ
ឬក៏រៀបចំឡើងដោយនរណាគេដែរ អ៊ុំស្រី?

ខៈ ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយ។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំស្រីហើយនឹងប្តីរបស់អ៊ុំស្រីបានជួបគ្នាលើកដំបូងនៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ នៅនឹងភូមិនឹង។

ក៖ ហើយអញ្ចឹង អ៊ុំស្រីស្គាល់គ្នាពីមុនរៀបការ ឬក៏ឪពុកម្តាយណែនាំអោយស្គាល់គ្នាទេ?

ខ៖ ឪពុកម្តាយគាត់ណែនាំអោយជួបគ្នាទៅ គាត់មើលទៅពិបាកពេក គាត់ក៏រៀបចំអោយទៅ។

ក៖ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹង ពេលដែលរៀបចំនឹងដូចជាមានថ្លៃជំនួនទេ អ៊ុំស្រី?

ខ៖ អត់មានជំនួនមានអីទេ កាលហ្នឹងដូចថា ពួកពលពតចាប់យើងអោយរៀបការ។

ក៖ អូ! អញ្ចឹងមានន័យថាអត់មានថ្លៃជំនួនទេ។ ហើយអញ្ចឹង សំរាប់អ៊ុំស្រីហើយនឹងលោកពូ
មានកូនចំនួនប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខ៖ មានកូនម្នាក់ ប៉ុន្តែកូនស្លាប់ហើយ កូនស្រី។

ក៖ អូ! មានកូនម្នាក់ប៉ុន្តែគាត់បានស្លាប់ហើយ! ហើយអញ្ចឹង
តើកូនស្រីរបស់អ៊ុំស្រីគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ៊ុំស្រី?

ខ៖ កូនស្រីរបស់ខ្ញុំគាត់ស្លាប់ដោយសារជម្ងឺ។

ក៖ ហើយអញ្ចឹង កូនស្រីរបស់អ៊ុំស្រីពេលដែលគាត់បានស្លាប់នឹង តើគាត់មានអាយុប៉ុន្មានឆ្នាំហើយ
អ៊ុំស្រី?

ខ៖ កូនស្រីរបស់ខ្ញុំពេលស្លាប់នឹងអាយុប្រហែលម្ភៃឆ្នាំ។

ក៖ អូ! គាត់អាយុម្ភៃឆ្នាំហើយ អញ្ចឹងធំហើយបានស្លាប់។ ហើយអញ្ចឹង
តើប្តីរបស់អ៊ុំស្រីគាត់បានស្លាប់នៅក្នុងឆ្នាំណា អ៊ុំស្រីមាននៅចាំទេ?

ខ៖ អេ៎! តានឹងមិនដឹងជាស្លាប់ឆ្នាំណាទេ ភ្លេចដែលនឹងរវីរវល់ច្រើនពេកមិនបានគិតឆ្នាំទេ។

ក៖ ហើយអញ្ចឹង ពេលប្តីរបស់អ៊ុំស្រីគាត់ស្លាប់នឹង តើគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខ៖ ប្តីរបស់ខ្ញុំពេលគាត់ស្លាប់នឹងអាយុប្រហែលហុកហើយមិនដឹង ខ្ញុំមិនសូវជាដឹងដែរ។

ក៖ អូ! អ៊ុំស្រីមិនសូវចាំដែរ។ ហើយអញ្ចឹងសំរាប់អ៊ុំស្រីចេះអានហើយនឹងសរសេរអក្សរខ្មែរទេ អ៊ុំស្រី?

ខ៖ មិនចេះទេ អក្សរក៏ខ្ញុំមិនចេះដែរ។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ អ៊ុំស្រី?

ខ៖ អត់ចេះទេ។

កៈ អត់ដែលចេះសោះ! ហើយអញ្ចឹង
អ៊ុំស្រីធ្លាប់មានមិត្តភក្តិជិតស្និតអីដែលធំធាត់មកជាមួយគ្នានៅក្នុងភូមិនឹងទេ អ៊ុំស្រី?

ខៈ ខ្ញុំមិនដែលមានទេ ខ្ញុំមិនដែលមានមិត្តភក្តិទេតាំងពីដើមមក។

កៈ ហើយអញ្ចឹង សព្វថ្ងៃនេះអ៊ុំស្រីមានធ្វើស្រែចំការទេ អ៊ុំស្រី?

ខៈ អត់ទេ គ្មានស្រែគ្មានចំការទេ អត់មានធ្វើទេរាល់ថ្ងៃនឹង។

កៈ នៅតែផ្ទះទេ អ៊ុំស្រី! ហើយអញ្ចឹង សព្វថ្ងៃនេះអ៊ុំស្រីធ្វើអ្វីដែរសំរាប់ចិញ្ចឹមជីវិតដែរ អ៊ុំស្រី?

ខៈ រាល់ថ្ងៃនឹងនៅស៊ីដោយសារប្អូនទេ គ្មានធ្វើអីកើតទេ។

កៈ អូ! អញ្ចឹងប្អូនគាត់ជួយផ្គត់ផ្គង់អោយ។
ហើយអញ្ចឹងសំរាប់អ៊ុំស្រីគិតថាជីវិតរបស់អ៊ុំស្រីតាំងពីក្មេងរហូតមកដល់ពេលនេះ
តើជីវិតរបស់អ៊ុំស្រីមានការផ្លាស់ប្តូរទេ អ៊ុំស្រី?

ខៈ មានផ្លាស់ប្តូរទៅណា នៅតែប៉ុននឹង។

កៈ នៅតែប៉ុននឹង! ចង់និយាយពីការលំបាកអី អ៊ុំស្រីមានការផ្លាស់ប្តូរទេ?

ខៈ គ្មានលំបាកគ្មានអីទេខ្ញុំ វាមិនសូវពិបាក ដូចថាយើងទៅស៊ីឈ្នួលគេចឹង
គេអាណិតដែរគេមិនចង់អោយយើងចេញអីចឹងណា គេមិនដែលធ្វើបាបអីទេ។

កៈ អញ្ចឹងមានន័យថា ជីវិតរបស់អ៊ុំស្រីធម្មតារហូតមកមិនសូវពិបាកខ្លាំងទេ។ ហើយអញ្ចឹង
សំរាប់ម្ហូបវិញ តើអ៊ុំស្រីចូលចិត្តហូបម្ហូបអីជាងគេ?

ខៈ ម្ហូបរាល់ថ្ងៃនេះចូលចិត្តតែសម្លម្ជូរ សម្លប្រហើរអីតែចឹង បន្លែអី បន្លែធម្មជាតិ ផាងត្រាវ ផាងក្តាច
ត្រកួន។

កៈ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរដូចជា បោះឈូល ចោលអង្គញ់ ទាញព្រ័ត្រ
តើអ៊ុំស្រីមានចូលចិត្តលេងល្បែងអីទេ តាំងពីក្មេងមក?

ខៈ តាំងពីក្មេងមកមិនដែលលេងទេ។

កៈ មិនដែលលេងសោះតែម្តង។

ខៈ មិនដែលលេងទេ ខ្លាចឈឺ។

កៈ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ តើអ៊ុំស្រីមានចូលចិត្តស្តាប់បទចម្រៀងអីទេ អ៊ុំស្រី?

ខៈ មិនដែលទេ ព្រោះអត់មានអីស្តាប់ ស្អីក៏គ្មានដែរ តែបើលោកទេស(ទេសមានន័យថា
លោកសង្ឃនិយាយធម៌អោយស្លាប់)ចូលចិត្តស្តាប់។

កៈ អូ! ចូលចិត្តស្តាប់លោកទេសធម៌។ ហើយអញ្ចឹងសំរាប់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំស្រីមាននរណាម្នាក់ដែលគាត់ចេះលេងឧបករណ៍ភ្លេងទេ អ៊ុំស្រី?

ខៈ អត់មានទេ។

កៈ ហើយអញ្ចឹង សំរាប់ផ្ទះអ៊ុំស្រីកាលពីអ៊ុំស្រីនៅតូចៗ តើផ្ទះនឹងផ្ទះរបៀបណាដែរ អ៊ុំស្រី?

ខៈ កាលពីនៅតូចៗផ្ទះតូចប្រក់ស្បូវជញ្ជាំងរហោករហែក។

កៈ ហើយអញ្ចឹង ផ្ទះនឹងជាផ្ទះទាប ឬមួយផ្ទះខ្ពស់ដែរ អ៊ុំស្រី?

ខៈ ផ្ទះខ្ពស់ដែរតែគ្រាន់តែវាទាប ផ្ទះកាំជណ្តើរបីកាំ។

កៈ អូ! ផ្ទះកាំជណ្តើរបីកាំ។ ហើយអញ្ចឹង តើផ្ទះនឹងនរណាគេជាអ្នកធ្វើដែរ អ៊ុំស្រី?

ខៈ អូ! ផ្ទះនឹងផ្ទះប្អូន។

កៈ អត់ផ្ទះដែលអ៊ុំស្រីនៅពីតូចនឹង?

ខៈ អូ! ផ្ទះនឹងផ្ទះជំនាន់ពលពត។

កៈ អញ្ចឹងផ្ទះនឹងគេចែកអោយ ឬមួយយ៉ាងម៉េចដែរ អ៊ុំស្រី?

ខៈ ផ្ទះនឹងគេចែកអោយ។

កៈ អូ! អញ្ចឹងផ្ទះនឹងអត់បានធ្វើខ្លួនឯងទេ ពេលយើងចេញពីសម័យពលពតមកគេចែកអោយ។ ហើយអញ្ចឹងសំរាប់អ៊ុំស្រីមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេ ដូចជា វេញវល្លិ៍ផ្តៅ ឬជំនាញកូរស្ករត្នោត ឬត្បាញអីចឹងណា?

ខៈ អត់ទេ គ្មានទេ អត់មានបន្តអីទេ ស្អីក៏គ្មានដែលខ្ញុំនោះ។

កៈ អញ្ចឹង តើជីវិតរបស់អ៊ុំស្រីមានបានឆ្លងកាត់សម័យសង្គ្រាមទេ អ៊ុំស្រី?

ខៈ ឆ្លងកាត់តាំងពីសង្គ្រាម រត់ជំនាន់ពលពតនឹងមកជាមួយយាយតា។

កៈ ហើយអញ្ចឹង ជំនាន់អាពតនឹងគេយកអ៊ុំស្រីទៅណា ហើយគេអោយអ៊ុំស្រីធ្វើអ្វីខ្លះដែរ អ៊ុំស្រី?

ខៈ កាលជំនាន់ពលពតគេយកខ្ញុំទៅអូសអួន។

កៈ នៅកន្លែងណាដែរ អ៊ុំស្រី?

ខៈ អូសអួននៅទន្លេយើងនឹង។

កៈ អញ្ចឹងអត់បានទៅណាឆ្ងាយទេ។ ហើយអញ្ចឹងសំរាប់អ៊ុំស្រី
តើអ៊ុំស្រីធ្លាប់មានពេលដែលលំបាកជាងគេនៅក្នុងជីវិតទេ?

ខៈ ពិបាកវាពិបាកហើយរាល់ថ្ងៃនឹង។

កៈ តែពេលណាដែលអ៊ុំស្រីគិតថាពិបាកជាងគេបំផុត?

ខៈ ពិបាកជាងគេបំផុតរឿងឈឺតែម្តង ឡើងឈាមផងអីផង។

កៈ ហើយអញ្ចឹងសំរាប់អ៊ុំស្រីធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតទេ ដូចជារៀបការកូន
ឬក៏បុណ្យទានអីនៅក្នុងផ្ទះ ធ្លាប់មានទេ អ៊ុំស្រី?

ខៈ ធ្លាប់មានការកូន ធ្វើបុណ្យធ្វើទានយើងធ្វើបានល្អដែរ។

កៈ ហើយអញ្ចឹង ពេលដែលមានកម្មវិធីនឹងកើតឡើងម្តងៗ តើអ៊ុំស្រីមានអារម្មណ៍យ៉ាងដូចម្តេចដែរ
អ៊ុំស្រី?

ខៈ មានអារម្មណ៍សប្បាយ។

កៈ ហើយអញ្ចឹងពេលដែលអ៊ុំស្រីនៅក្មេង តើអ៊ុំស្រីធ្លាប់មានក្តីសង្ឃឹមថា
ធំឡើងអ៊ុំស្រីចង់ធ្វើអ្វីមួយទេ អ៊ុំស្រី?

ខៈ នៅពីក្មេងធំដឹងក្តីទៅចង់តែធ្វើស្រែ។

កៈ អូ! អ៊ុំស្រីចង់ធ្វើស្រែ! ហើយអញ្ចឹងសំរាប់ចុងក្រោយ
បើសិនជាអ៊ុំស្រីចង់ផ្តែផ្តាំទៅកាន់កូនចៅជំនាន់ក្រោយ តើអ៊ុំស្រីចង់ផ្តាំអ្វីខ្លះដែរ អ៊ុំស្រី?

ខៈ ខ្ញុំគ្មានអីផ្តែផ្តាំទេ។

កៈ ហើយអញ្ចឹង អ៊ុំស្រីមានចង់អោយគាត់ធ្វើអ្វីទេ អ៊ុំស្រី?

ខៈ កូនចៅវានៅឆ្ងាយពេកវាគ្មានបានអីផ្តែផ្តាំទេ បើខែភ្ជុំវាមកពីរបីថ្ងៃអីទៅវិញហើយ
មកនឹងវាប្រញាប់ទៅវិញហើយ។

កៈ
អញ្ចឹងចុងក្រោយអរគុណអ៊ុំស្រីច្រើនសំរាប់ពេលវេលាដែលអ៊ុំស្រីអោយខ្ញុំសម្ភាសន៍អំពីប្រវត្តិរបស់អ៊ុំស្រី ហើយចុងក្រោយសូមជូនពរអ៊ុំស្រីសូមអោយអ៊ុំស្រីមានសុខភាពល្អមានកំលាំងមាំមួន
ហើយមានប្រាជ្ញាវៀងវៃ ហើយសូមជូនពរដល់កូនចៅរបស់អ៊ុំស្រីផងដែរ
សូមអោយពួកគាត់មានសុខភាពល្អ មានកំលាំងមាំមួន ហើយមានប្រាជ្ញាវៀងវៃ
សូមអោយគាត់ជោគជ័យលើមុខរបររកស៊ីរបស់គាត់រាល់ថ្ងៃ។ អញ្ចឹង អរគុណច្រើនណាស់អ៊ុំស្រី។